ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈ នៃការយោគយល់

រវាង

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

និង

ក្រុមហ៊ុន សាស្ត្រា ឯ.ក

ស្តីពី

កិច្ចសហប្រតិបត្តិការ និងការលើកកម្ពស់ប្រសិទ្ធភាពការងារផ្សព្វផ្សាយ អប់រំ
អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ឆ្នាំ ២០២៥ - ២០២៧

## បុព្វកថា

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងក្រុមហ៊ុនសាស្ត្រា ឯ.ក ដែលតទៅនេះកំណត់ថា «គូភាគី» ដោយហេតុថា៖

- គូភាគីមានបំណងធ្វើកិច្ចសហប្រតិ្តការលើការងារ បង្ការ ទប់ស្កាត់ បទល្មើសជួញដូរមនុស្សគ្រប់ទម្រង់ ឱ្យកាន់តែមានប្រសិទ្ធភាពនៅកម្ពុជា។
- ក្រុមហ៊ុនសាស្ត្រា ឯ.ក ជាក្រុមហ៊ុនមានឯកទេសខ្ពស់ក្នុងការផលិតភាពយន្ត មានការចូលរួមសកម្មភាពល្អៗជាច្រើន ជូនសង្គមជាតិ សម្រាប់ធ្វើការផ្សព្វផ្សាយអប់រំ ជូនប្រជាពលរដ្ឋកម្ពុជា តាមរយៈភាពយន្តដែលបាននិងកំពុងផលិត ដើម្បីបានយល់ដឹងបន្ថែម អំពីផលប៉ះពាល់ផ្សេងៗដែលកើតចេញពីអំពើជួញដូរមនុស្ស។
- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស យោងតាមយុទ្ធសាស្ត្រទី១ លើកកម្ពស់ការបង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ (ចង្កោមសកម្មភាព១.៧) នៃផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០២៤-២០២៨ ដែលជម្រុញដល់ការចូលរួមពីវិស័យឯកជនក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់។
- គូភាគីត្រូវឈរលើមូលដ្ឋាន នៃផលប្រយោជន៍ទៅវិញទៅមក និងតម្រូវការរបស់ភាគីនីមួយៗក្នុងកិច្ចសហការប្រតិបត្តិការ ដើម្បីបង្ការទប់ស្កាត់បទល្មើសជួញដូរមនុស្សគ្រប់ទម្រង់ ការកេងប្រវ័ញ្ច ការរំលោភបំពាន និងបទល្មើសពាក់ព័ន្ធ តាមប្រព័ន្ធអនឡាញ កិច្ចការជាដៃគូត្រូវបានចែងក្នុងអនុស្សរណៈនៃការយោគយល់។

ដោយគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៃព្រះរាជាណាចក្រកម្ពុជាគូភាគីបានព្រមព្រៀងដូចតទៅ៖

## ផ្នែកទី១

## គោលបំណង

**ប្រការ ១ ._** - ពង្រឹងកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការងារផ្សព្វផ្សាយអប់រំ អំពី អំពើកេងប្រវ័ញ្ច និងជួញដូរមនុស្សគ្រប់ទម្រង់ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិ ផលប្រយោជន៍ស្របច្បាប់ និងអាយុជីវិតរបស់បុគ្គល និងសន្តិសុខសុវត្ថិភាពសង្គមជាតិ។

- រួមចំណែកធ្វើឱ្យសម្រេចនូវឆន្ទៈដ៏មុតស្រួចរបស់រាជរដ្ឋាភិបាល ក្នុងការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើកេងប្រវ័ញ្ច និងជួញដូរមនុស្សគ្រប់ទម្រង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការគាំទ្រដល់ការផលិត និងផ្សព្វផ្សាយភាពយន្តដែលមានអត្ថន័យអប់រំសង្គម និងផ្តល់
- ឧក្រិដ្ឋ កម្មកាចសាហាវនេះ។

## ផ្នែកទី២
## ការទទួលខុសត្រូវរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មការជាតិ
## ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**ប្រការ ២** ._- ផ្ដល់គំនិតយោបល់លើខ្លឹមសារ ទិដ្ឋភាពសង្គម បច្ចេកទេសច្បាប់ ទិន្នន័យ សម្ភារៈ និងឯកសារពាក់ព័ន្ធចាំបាច់ កិច្ចសម្ភាសន៍ និងសម្របសម្រួល ជាមួយបុគ្គលពាក់ព័ន្ធ អំពីទិដ្ឋភាព និងផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ការធ្វើទេសន្តប្រវេសន៍ ឬចំណាកស្រុកដោយប្រថុយប្រថានការកេងប្រវ័ញ្ច ការរំលោភបំពាន និងបទល្មើសពាក់ព័ន្ធនឹងប្រព័ន្ធអនឡាញ ដែលឈានទៅដល់អំពើជួញដូរមនុស្ស ដើម្បីផ្ដល់កិច្ចសហការ និងការគាំទ្រលើទិដ្ឋភាពច្បាប់ និងសង្គមសម្រាប់ការផ្សព្វផ្សាយអប់រំឱ្យបានត្រឹមត្រូវ។

- ស្នើសុំការសម្រេច និងគាំទ្រពី អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ លើខ្លឹមសារ ដំណើរការ និងការសម្របសម្រួល ក្នុងការទំនាក់ទំនងជាមួយក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ។
- ចូលរួមពិនិត្យ សម្របសម្រួល និងស្នើសុំកិច្ចសហការ និងជំនួយបច្ចេកទេសពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មុននឹងឯកភាពជាចុងក្រោយលើមាតិកាភាពយន្តដែលបានផលិត។
- ចាត់តាំងមន្ត្រីតំណាងអគ្គលេខាធិការដ្ឋាននៃគ.ជ.ប.ជ ដើម្បីចូលរួមសហការសម្របសម្រួលគាំទ្រក្នុងកិច្ចការនានា ដូចមានចែងក្នុងអនុស្សរណៈ ដោយមិនគិតការចំណាយជាបន្ទុករបស់ក្រុមហ៊ុនសាស្ត្រា ឯ.ក ឡើយ។
- សម្របសម្រួលដល់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ឱ្យចូលរួមគាំទ្រដំណើរការផលិតខ្សែភាពយន្ត និងមាតិការបស់ក្រុមហ៊ុន សាស្ត្រាហៀម ឯ.ក តាមចាំបាច់ ព្រមទាំងការផ្សព្វផ្សាយ ឱ្យស្របតាមគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។
- ចូលរួមត្រួតពិនិត្យ កែលម្អ ប្រកបដោយការទទួលខុសត្រូវ លើខ្លឹមសារ និងបច្ចេកទេសនៃការបង្ហាញរូបភាព និងខ្លឹមសារដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងទម្រង់ពាក់ព័ន្ធដទៃទៀត មុននឹងដាក់បញ្ចាំង ឬផ្សព្វផ្សាយជាសាធារណៈ ដោយធានាថា មិនមានផលប៉ះពាល់ជាអវិជ្ជមានដល់សុវត្ថិភាព និងចិត្តសាស្ត្រសង្គម ។
- អនុញ្ញាតឱ្យក្រុមហ៊ុនសាស្ត្រា ឯ.ក ប្រើប្រាស់និមិត្តសញ្ញា របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (Logo) និងឈ្មោះសមាជិក ដែលតំណាងអគ្គលេខាធិការដ្ឋាន នៃ គ.ជ.ប.ជ ដែលបានចូលរួម ដាក់នៅក្នុង CREDIT នៃខ្សែភាពយន្តពាក់ព័ន្ធដូចជា «សហការផលិត» (ក្នុងករណីឧបត្ថម្ភថវិកាលើគម្រោងផលិតទាំងមូល) ឬ «គាំទ្រ» ឬ «ប្រឹក្សាយោបល់ (មិនមានការឧបត្ថម្ភថវិកា)» ដោយ គ.ជ.ប.ជ ឬ CREDIT សមស្របផ្សេងទៀតដែលនឹងរៀបចំដោយ ក្រុមហ៊ុនសាស្ត្រា ឯ.ក ។
- ចូលរួមជំរុញ និងចែករំលែកការផ្សព្វផ្សាយ ការចាក់បញ្ចាំងជាសាធារណៈ តាមប្រព័ន្ធផ្សព្វផ្សាយនានា និងតាមបណ្ដាញសង្គម ឱ្យទូលំទូលាយនូវភាពយន្តដែលផលិតបានដោយក្រុមហ៊ុនសាស្ត្រា ឯ.ក ។

## ផ្នែកទី៣
## ការទទួលខុសត្រូវរបស់ក្រុមហ៊ុនសាស្ត្រា ឯ.ក

**ប្រការ ៣ ._-** ផលិតភាពយន្ត ដែលមានខ្លឹមសារផ្សព្វផ្សាយអប់រំសង្គមឲ្យយល់ដឹងអំពីអំពើជួញដូរមនុស្ស និងផលប៉ះពាល់ទៅលើជីវិតឯកជន និងសង្គមជាតិ ក៏ដូចជាការធ្វើទេសន្តរប្រវេសន៍ ឬចំណាកស្រុក ការកេងប្រវ័ញ្ច ការរំលោភបំពានលើកុមារ និងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ នៅក្នុងភាពយន្តជីវិត ដោយផលិតយ៉ាងតិចបំផុត០៣(បី)ភាពយន្តក្នុង០១(មួយ)ឆ្នាំ។

- ចូលរួមផលិតមាតិកាអប់រំខ្លី ទាក់ទងនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងបទល្មើសពាក់ព័ន្ធ សម្រាប់ ទិវាជាតិ ០១មាតិកា/ភាពយន្ត/ភាពយន្តជីវិត ក្នុងមួយឆ្នាំ។
- ការចំណាយក្នុងការផលិត វិធីសាស្ត្រក្នុងការរកចំណូល និងចំណូលបានមកពីការធ្វើអាជីវកម្មលើមាតិកាភាពយន្ត គឺជាសិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុនសាស្ត្រា ឯ.ក។
- ទទួលយកការផ្តល់យោបល់ និងការកែលម្អពីអ្នកជំនាញពាក់ព័ន្ធរបស់ គ.ជ.ប.ជ ដើម្បីធានាថាភាពយន្ត ឬមាតិកា ដែលចេញផ្សាយទៅមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់សុវត្ថិភាព និងចិត្តសាស្ត្រសង្គម ។
- មិនគាំទ្រ និងអនុញ្ញាតឱ្យបុគ្គលិករបស់ខ្លួនចូលរួមនូវរាល់សកម្មភាពទាំងឡាយណា ដែលអាចប៉ះពាល់ដល់សុវត្ថិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម ឬសកម្មភាពដទៃទៀតដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជា។ បុគ្គលិកដែលប្រព្រឹត្តសកម្មភាពខុសឆ្គងទាំងនេះ នឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។
- ផ្តល់របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ នូវតួលេខ ស្តីពីចំនួនអ្នកទស្សនាខ្សែភាពយន្ត និងមាតិកា ទាំងនៅរោងភាពយន្ត ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយសង្គម ព្រមទាំងចំនួនខ្សែភាពយន្ត និងមាតិកាដែលបានផលិតទាក់ទងនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់ មកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីឱ្យអគ្គលេខាធិការដ្ឋានរំលេចលទ្ធផលការងារសហប្រតិបត្តិការក្នុងរបាយការណ៍ជាតិ គ.ជ.ប.ជ។
- សេចក្តីសង្ខេបអំពីគម្រោង និងសកម្មភាពមនុស្សធម៌ជាក់ស្តែងរបស់អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា សហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ ត្រូវប្រតិបត្តិដូចមានចែងលម្អិតក្នុងឧបសម្ពន្ធ(១) និង (២) ។

## ប្រការ ៤
## គោលការណ៍រួម

**ប្រការ ៤ ._-** ការអនុវត្តអនុស្សរណៈ នៃការយោគយល់នេះ ត្រូវគោរពតាមគោលការណ៍សមភាព និងផលប្រយោជន៍រួម ដើម្បីធានាដល់កិច្ចសហប្រតិបត្តិការ និរន្តរភាព និងប្រសិទ្ធភាព នៃការអនុវត្ត។

- ការរៀបចំកិច្ចប្រជុំតាមដាន និងវាយតម្លៃកិច្ចសហប្រតិបត្តិការ ក្នុងការអនុវត្តអនុស្សរណៈយោគយល់នេះត្រូវធ្វើចំនួន០២(ពីរ)ដងក្នុង០១(មួយ)ឆ្នាំ។

- គូភាគី ឯកភាពរក្សាការសម្ងាត់ជូនគ្នាទៅវិញទៅមក ពាក់ព័ន្ធនឹងភាគី នីមួយៗ និងរក្សាកិត្តិយស និងសេចក្តីថ្លៃថ្នូរ របស់អង្គភាព និងស្ថាប័ន ឬការសម្ងាត់ជាតិ ជាដាច់ខាត។
- គូភាគីនឹងរក្សាជំហរសុចរិតរៀងខ្លួន មិនប្រើប្រាស់ឥទ្ធិពលរបស់ភាគីដោយផ្ទាំផ្ទួង ខុសសីលធម៌ ឬកេងចំណេញប្រយោជន៍ពីគ្នាឡើយ។

## ផ្នែកទី ៥

## ការដោះស្រាយវិវាទ

រាល់វិវាទដែលកើតឡើងពីការបកស្រាយ ឬការអនុវត្តនៃកិច្ចព្រមព្រៀងអនុស្សរណៈនេះ ត្រូវដោះស្រាយតាមរយៈការចរចា និងប្រឹក្សាយោបល់ប្រកបដោយការយោគយល់ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រុមហ៊ុនសាស្ត្រា ឯ.ក ។

## ផ្នែកទី ៦

## អវសានប្បញ្ញត្តិ

- អនុស្សរណៈ នៃការយោគយល់នេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។
- អនុស្សរណៈនៃការយោគយល់នេះអាចបញ្ចប់ដោយភាគីណាមួយក៏បានគឺបន្ទាប់ពី៦០(ហុកសិប) ថ្ងៃ ដែលភាគីនោះផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជូនទៅភាគីម្ខាងទៀត។
- អនុស្សរណៈ នៃការយោគយល់នេះ មានសុពលភាពរយៈពេលពីរឆ្នាំ និងអាចបន្តជាថ្មីបានក្នុងករណីមានការឯកភាពគ្នារវាងគូភាគី ។

អនុស្សរណៈ នៃការយោគយល់នេះ ធ្វើឡើងជាពីរច្បាប់ (ច្បាប់ដើម) ជាភាសាខ្មែរ នឹងមិនមានការបង្កើតសិទ្ធិ និងកាតព្វកិច្ចបន្ថែមណាមួយឡើយ ។

ថ្ងៃ.....៧.រោច..... ខែ.កត្តិក.. ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី..១៦... ខែ..វិច្ឆិកា.. ឆ្នាំ២០២.៥

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
**អនុប្រធានអចិន្ត្រៃយ៍**

**ជូ ប៊ុនអេង**

**ក្រុមហ៊ុន សាស្ត្រា ឯ.ក**
**ប្រធាន**

**ប៊ុន ចាន់និមល**